# ការណែនាំសង្ខេបអំពី សាលាថ្នាក់ K-12 ហាវ៉ៃ (HAWAI'I K-12 SCHOOLS)

## របៀបកាត់បន្ថយការរីករាលដាលកូវីត Covid-19 នៅសាលា



- **សូមរក្សាកាលបរិច្ឆេទចាក់វ៉ាក់សាំង - ការចាក់វ៉ាក់សាំងគឺជាយុទ្ធសាស្ត្រសំខាន់បំផុត** ដើម្បីការពារសិស្សនិងបុគ្គលិក
  - អ្នកដែលមានសិទ្ធិទទួលបានការចាក់វ៉ាក់សាំង ត្រូវចាក់វ៉ាក់សាំងកូវីត COVID-19 បន្តទៀត
  - ថ្នាំវ៉ាក់សាំងគឺឥតគិតថ្លៃ មានសុវត្ថិភាព និងជួយការពារប្រជាពលរដ្ឋពីការឈឺធ្ងន់ធ្ងរ ឬស្លាប់ដោយសារកូវីត COVID-19
- **សូមស្នាក់នៅផ្ទះពេលមានជំងឺ លើកលែងតែទៅទទួលការថែទាំសុខភាព**
- **ការពាក់ម៉ាស់** ផ្តល់ជូននូវកម្រិតការពារបន្ថែមដែលមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់អ្នកដែលមានហានិភ័យខ្ពស់ចំពោះជំងឺធ្ងន់ធ្ងរ។
- **លាងដៃឱ្យបានញឹកញាប់និងខ្ទប់មាត់ច្រមុះពេលក្អកនិងកណ្តាស់**

## ការណែនាំអំពីការស្ថិតនៅដោយឡែកពីអ្នកដទៃ



ប្រសិនបើអ្នកមានរោគសញ្ញា[1] ជំងឺកូវីត COVID-19 ឬតេស្ត**វិជ្ជមាន** COVID-19៖

- **មិនត្រូវទៅសាលារៀន ហើយជូនដំណឹងទៅសាលា**
- **សូមស្នាក់នៅផ្ទះ (នៅដាច់ដោយឡែកពីអ្នកដទៃ) លើកលែងតែមានការទទួលបានសេវាថែទាំសុខភាពហូតដល់៖**
  - **យ៉ាងតិច 5 ថ្ងៃពេញ** បន្ទាប់ពីរោគសញ្ញាដំបូងបានបង្ហាញ ឬបើគ្មានរោគសញ្ញានានាបន្ទាប់ពីការធ្វើតេស្ត **និង**
  - **យ៉ាងហោចណាស់ 24 ម៉ោង**ចាប់តាំងពីការក្តៅខ្លួនបានកន្លងផុតទៅ ដោយមិនប្រើថ្នាំបញ្ចុះកម្តៅ ហើយ
  - បើមានរោគសញ្ញាណាមួយបានធូរស្រាល
- នៅពេលអ្នកត្រឡប់ទៅសាលារៀនវិញ បន្ទាប់ពីការស្ថិតនៅនៅដាច់ដោយឡែកពីអ្នកដទៃនោះ **សូមពាក់ម៉ាស់ជិតឱ្យបានត្រឹមត្រូវនៅក្នុងផ្ទះរយៈពេល 5 ថ្ងៃពេញ**

[1] សិស្ស និងបុគ្គលិកដែលមានរោគសញ្ញាបន្តពីមូលហេតុផ្សេងទៀត (ឧទាហរណ៍ អាល់ឡែហ្ស៊ី ជំងឺហឺត) និងមិនស្គាល់ ការប៉ះពាល់នឹងជំងឺកូវីត COVID-19 មិនចាំបាច់ស្ថិតនៅដាច់ដោយឡែកពីអ្នកដទៃទេ លុះត្រាតែពួកគេមានរោគសញ្ញាថ្មី ឬកាន់តែធ្ងន់ធ្ងរ ឬធ្វើតេស្តវិជ្ជមានកូវីត COVID-19។

## ការណែនាំអំពីការប៉ះពាល់នឹងជំងឺឆ្លង



- **អ្នកអាចស្ថិតនៅសាលា បើអ្នកមិនមានរោគសញ្ញា**, ដោយមិនគិតពីស្ថានភាពការចាក់វ៉ាក់សាំងនោះទេ
- **សូមពាក់ម៉ាស់**នៅជុំវិញអ្នកដទៃនៅក្នុងផ្ទះរយៈពេល **10 ថ្ងៃ**
- ពិនិត្យមើលរោគសញ្ញាកូវីត COVID-19
- **ធ្វើតេស្តយ៉ាងហោចណាស់ 5 ថ្ងៃ បន្ទាប់ការប៉ះពាល់ឆ្លងជំងឺ** បើទោះបីអ្នកមិនមានរោគសញ្ញាក៏ដោយ
- បើមានរោគសញ្ញា ត្រូវស្ថិតនៅដោយឡែកពីអ្នកដទៃ ហើយធ្វើតេស្តភ្លាមៗ

- ការណែនាំអំពីសាលារៀន - **health.hawaii.gov/coronavirusdisease2019/resources/school-guidance/**
- វ៉ាក់សាំងកូវីត **COVID-19** - **HawaiiCOVID19.com/vaccine/**
- ធនធានជាពហុភាសា - **HawaiiCOVID19.com/translations/**

**ព័ត៌មានបន្ថែម សូមចូលទៅ HawaiiCOVID19.com**

បានកែសម្រួលនៅថ្ងៃទី 07/03/2023